# *ឈ្មោះទម្រង់ឈររបស់ទេពក្នុងសិល្បៈខ្មែរ*

*រាល់ទេពនិករទាំងអស់នៅក្នុងសិល្បៈខ្មែរ ទាំងក្នុងព្រហ្មញ្ញសាសនាក្ដី ព្រះពុទ្ធសាសនាក្ដី តែងតែមានទម្រង់ឈរជាច្រើនប្រភេទ អាស្រ័យទៅតាមបរិបទនិងគម្ពីរដែលគេយកមកឆ្លាក់។ ទម្រង់ឈរ និងអង្គុយទាំងអស់សុទ្ធសឹងតែមានឈ្មោះហៅផ្សេងៗពីគ្នា ដែលអាចឱ្យអ្នកសិក្សាអាចកំណត់បាន។ នៅក្នុងអត្ថបទខ្លីនេះ យើងនឹងលើកឡើងអំពីរបៀបហៅឈ្មោះទម្រង់ឈររបស់ទេពនិករក្នុងសិល្បៈខ្មែរ ពោល គឺរាប់បញ្ចូលទាំងបដិមាទោល ចម្លាក់ជាប់ជញ្ជាំងឥដ្ឋ ជញ្ជាំងថ្ម ។ល។ តើទម្រង់ឈររបស់ទេពនិករនៅក្នុងសិល្បៈខ្មែរ មានឈ្មោះហៅយ៉ាងដូចម្ដេចខ្លះ? តើទម្រង់ឈរទាំងនេះមានឥទ្ធិពលមកពីសិល្បៈណា?*

## ១. *ភង្គ* (bhaṅga)

***ភង្គ*** *សំដៅលើទម្រង់ឈរដែលមានលក្ខណៈពត់ពែន កោង បត់ ឬភាពអែនអនៃរាងកាយ ពោល គឺជាការឈរឱ្យមានលំនឹងតាមរយៈភាពបត់បែននៃរាងកាយ។*[១] *ទម្រង់នេះមានលក្ខណៈខុសពីទម្រង់មួយទៀតដែលគេហៅថា "**សមបាទស្ថានក**"* (sasmapădasthănaka) *ដែលជាទម្រង់រូបឡើងត្រង់ដោយមិនមានការពត់ពែន អែនអន ឬរំកិលទម្ងន់ចេញពីចំណុចកណ្ដាលនៃទំនាញ ឬខ្សែបន្ទាត់នៃរូបរាងកាយ ហើយដៃ និងជើងដាក់ក្នុងលំនឹងដោយសម្ទឹងមើលផ្ទាល់។ ជាទូទៅ គេអាចកំណត់រូបមួយអាចជាទម្រង់ភង្គបានតាមរយៈខ្សែបំពង់ ឬខ្សែអ័ក្សកណ្ដាល ដែលជាខ្សែរត់កាត់ពីក្បាលចុះមកក្រោមកាត់តាមថ្ងាស ច្រមុះ ចង្កា ផ្ចិតទ្រូង ប្រដាប់ភេទ ចន្លោះភ្លៅ និងជើងដែលគេច្រើនហៅថា "**មធ្យសុត្រ**"* (madhyasutra) *ឬ "**បុរ័សុត្រ**"* (purvasutra)*។*[២]

*គេបែងចែកទម្រង់ "ភង្គ" ជាបីប្រភេទគឺ អភង្គ* (abhaṅga) *សមភង្គ* (samabhaṅga) *និងអតិភង្គ* (atibhaṅga)*។ ដោយសារទម្រង់ "ភង្គ" មានបីប្រភេទ ទើបគេនិយមហៅទម្រង់ឈរនេះថា "ត្រិភង្គ"* (tribhaṅga) *ដែលប្រែថា កាយវិការអែនអនរាងកាយទាំងបី។ អភង្គ សំដៅលើភាពបត់បែន ពត់ពែន ឬអែនអននៃរាងកាយមានកម្រិតតិចតួច តំណាងឱ្យភាពស្ងប់ស្ងាត់ និងទន់ភ្លន់នៃសាត្វិកភាវ* (sătvikabhăva)*។ សមភង្គ សំដៅលើភាពបត់បែននៃរាងកាយកម្រិតមធ្យម តំណាងឱ្យភាពត្រេកត្រអាល* (śṛṅgāra) *និងចំណង់ចំណូលចិត្ត* (rajasa) *ហើយអតិភង្គ សំដៅដល់ភាពបត់បែននៃរាងកាយកម្រិតខ្លាំងដែលតំណាងឱ្យការឈ្លានពាន និងមោទនភាពនៃភាពក្លាហាន* (vira)*។*[៣]

---

[១] Berkson 2000.

[២] Ganapati 2002.

[៣] Ibid.

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*

នៅក្នុងសិល្បៈខ្មែរទេពនិករដែលមានទម្រង់ភង្គ ឬត្រិភង្គ បែបនេះ គេនិយមខ្លាំងណាស់ ហើយបើនៅសម័យដំបូងៗវិញយើងជឿថា សិល្បករខ្មែរទំនងទទួលឥទ្ធិពលសិល្បៈឥណ្ឌា។ រូបទាំងនោះមានដូចជា បដិមាព្រះពុទ្ធរកឃើញនៅវត្តរំលក ស្រុកអង្គរបុរី ខេត្តតាកែវ (រូបលេខ១) ចម្លាក់ព្រះពោធិសត្វកាន់ផ្កាឈូកឆ្លាក់លើថ្មគោលកំពុងដាក់តាំងនៅសារមន្ទីរអង្គរបុរី (រូបលេខ២) បដិមាព្រះរាមរកឃើញនៅភ្នំដា (រូបលេខ៣) បដិមាបរសុរាមរកឃើញនៅភ្នំដា[៤] (រូបលេខ៤)។ល។ ក្នុងចំណោមរូបដែលលើកឧទាហរណ៍ខាងលើនេះ សុទ្ធសឹងមានទម្រង់បត់បែនព្រះកាយកម្រិតតូចដែលអាចស្ថិតនៅក្នុងទម្រង់ទី១នៃភង្គ ដែលយើងហៅថា "អភង្គ" តំណាងឱ្យភាពស្ងប់ស្ងាត់ និងភាពទន់ភ្លន់។

## ២. ស្ថានក (sthănaka)

ស្ថានក សំដៅដល់ទម្រង់ឈរត្រង់របស់រូបដែលពុំមានពត់ពែន ឬអែនអននៃរាងកាយដូចទម្រង់ភង្គឡើយ។ ជាទូទៅ ទម្រង់"ស្ថានក" ដែលគេស្គាល់នោះគឺ "សមបាទស្ថានក" (sasmapăda sthănaka)។[៥] សមបាទស្ថានក គឺជាឥរិយាបថឈរដ៏មានលំនឹងរឹងមាំមួយដែលមានជើងស្មើទៅនឹងខ្សែអ័ក្សកណ្ដាលនៃរូប (មជ្ឈសូត្រ) ក្បាល និងដងខ្លួនដាក់ឱ្យត្រង់ ជើង និងដៃនៅជាប់គ្នា រាងកាយគ្មានការបត់បែនទៅទិសណាមួយ ហើយសម្លឹងឆ្ពោះទៅមុខត្រង់។ ទម្រង់ខ្លះទៀតនៃសមបាទស្ថានក គឺសំដៅលើឥរិយាបថដែលដៃដាក់កាន់មុទ្រ ឯរាងកាយនៅឈររឹងមាំ។ ទម្រង់សមបាទស្ថានក គេចែកចេញជាពីរទៀតគឺ វៃតស្ថិកស្ថានក (vaitasthikasthănaka) សំដៅដល់ឥរិយាបថឈរត្រង់ដោយដាក់ម្រាមជើងទាំងសងខាងកន្ធែកចេញពីគ្នា តែកជើងដាក់ទន្ទឹមគ្នាដដែល និងអធ៌វៃស្ថិកស្ថានក (Ardhavaitasthikasthănaka) សំដៅដល់ឥរិយាបថឈរត្រង់ដោយដាក់ម្រាមជើងខាងស្ដាំងាកចេញទៅស្ដាំ និងម្រាមជើងឆ្វេងដាក់ទៅមុខត្រង់។[៦]

នៅក្នុងសិល្បៈខ្មែរ ទម្រង់ឈរសមបាទស្ថានក ពេញនិយមខ្លាំងណាស់ ឧទាហរណ៍ រូបលោកេស្វររកឃើញនៅស្រះនាងតាសុខ ខេត្តបន្ទាយមានជ័យ (រូបលេខ៥) រូបព្រះសិអារ្យមេត្រិយ៍រកឃើញនៅទួលអង្គរិល ខេត្តកំពង់ស្ពឺ (រូបលេខ៦)។ល។ ឧទាហរណ៍ទាំងពីរនេះ សុទ្ធសឹងបង្ហាញអំពីទម្រង់សមបាទស្ថានក ហើយនៅក្នុងសិល្បៈខ្មែរយើងកម្របានជួបរូបទេពដែលឈរក្នុងទម្រង់

---

[៤] Dupont 1955.

[៥] Ganapati 2002.

[៦] Ibid.

វៃតស្តិកស្ថានក និងអធ៌វៃស្តិកស្ថានកណាស់ ផ្ទុយពីសិល្បៈឥណ្ឌាសម្បូណ៌ទម្រង់នេះណាស់ (រូបលេខ៧-៨)។

### ៣. ស្ថានសន (sthănasana)

ស្ថានសន សំដៅលើទម្រង់ឈរជាច្រើនប្រភេទទៀត ក្រៅពីទម្រង់ឈរដែលបានរៀបរាប់ខាងលើ ដែលក្នុងនោះមានដូចជា ស្វស្តិកសន (swastikasana) អលិទិសន (alidisana)។ល។ ស្វស្តិកសន ជាទម្រង់ឈរដែលយកជើងឆ្វេងដាក់ត្រង់លើដី និងជើងស្តាំដាក់បញ្ឈរខ្វែងមកខាងឆ្វេងប៉ះជាមួយដីដោយម្រាមជើងស្តាំ។[៧] ទម្រង់នេះ យើងឃើញនៅក្នុងសិល្បៈខ្មែរត្រង់ឈុតព្រះក្រឹស្ណទ្រភ្នំគោវធ៌ន[៨] (រូបលេខ៩-១០) រូបព្រះឥសូរក្នុងទម្រង់កិក្សាដនមូតិ៌[៩] (រូបលេខ១១) ។ល។

ទម្រង់ឈរមួយទៀតមានឈ្មោះថា "អលិទិសន" គឺជាទម្រង់ឈរដែលយកជើងឆ្វេងដាក់ទៅមុខ ជើងស្តាំដាក់ទៅក្រោយ ក្នុងកាយវិការកំពុងយកដៃបាញ់ធ្នូ។ នៅក្នុងឥរិយាបថបែបនេះ នៅក្នុងសិល្បៈខ្មែរ ច្រើនបង្ហាញជារូបព្រះរាមបាញ់ធ្នូ ដូចជាឈុតពាលី និងសុគ្រីពប្រយុទ្ធគ្នា ឧទាហរណ៍ ចម្លាក់នៅហោជាងប្រាសាទបន្ទាយស្រី (រូបលេខ១២)។[១០]

ក្រៅពីទម្រង់ឈរខាងលើ នៅមានទម្រង់ជាច្រើនទៀត ដែលមិនសូវនិយមនៅក្នុងសិល្បៈខ្មែរ ដូចជា វៃសខស្ថានក (vaisakhasthănaka) វៃស្នវ (vaishnava) ប្រត្យាលិទសន (pratyălidasana) ឧធ៌វជនុ (urdhavajanu) ឯកបាទស្ថានក (ekapădasthănaka)។ល។[១១]

ជារួមមក ទម្រង់ឈររបស់ទេពនិករនៅក្នុងសិល្បៈខ្មែរមានលក្ខណៈសម្បូណ៌បែបណាស់ ហើយទម្រង់ទាំងនោះស្ទើរតែទាំងអស់ខ្មែរបានទទួលឥទ្ធិពលពីសិល្បៈឥណ្ឌា។ ទម្រង់ឈរនីមួយសុទ្ធសឹងមានអត្ថន័យនិងផ្ទត់គំនិតខាងក្នុង។ យ៉ាងណាក៏ដោយ ទម្រង់ដែលបានបង្ហាញខាងលើគ្រាន់តែជាការបង្ហាញទម្រង់ខ្លះៗប៉ុណ្ណោះ៕

## ឯកសារយោង

[៧] Ganapati 2002.

[៨] Roveda 2005.

[៩] Giteau 1965.

[១០] Roveda 2005.

[១១] Ganapati 2002.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

**Berkson, Carmel**
2000, *The life of form in Indian sculpture,* Abhinav Publications.
**Ganapati, Sthapati, V.**
2002, *Indian sculpture & iconography, forms and measurements,* Sri Aurobindo Institute of Research in Social Sciences, India.
**Madeleine, Giteau**
1965, 'Une representation de la Bhikatanamurti de Shiva à Angkor Vat', *Art Asiatiques,* Tome XI, Paris.

**Pierre, Dupont**

1955, 'La statuaire Préangkoienne', *Artibus Asiae, Supplementum,* Vol 15, available online [ https://www.jstor.org/stable/1522585 ] .

**Roveda, Victorio**
2005, "*Image of the gods*", Bangkok.




រូបលេខ១.២៖ បដិមាព្រះពុទ្ធរូបរកឃើញនៅវត្តរំលក និងចម្លាក់ព្រះពោធិសត្វឆ្លាក់នៅលើថ្មគោល


បី


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION





AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION



AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

ដោយ៖ ម៉ង់ រ៉ាលី



AMS



រូបលេខ១០៖ ចម្លាក់ព្រះក្រឹស្ណទ្រភ្នំគោវធ៌ននៅប្រាសាទស្រីគ្រប់ល័ក្ខណ
និងបង្ហាញពីទម្រង់ឈររបស់ព្រះក្រឹស្ណបែប ស្វស្តិកសន (រូបថត៖ លួន ទីយា)



AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION



AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី